# ខ្លឹមសារសង្ខេប សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ លោកស្រី អៀង ធីរិទ្ធ ពាក់ព័ន្ធសំណើសុំព្យួរនីតិវិធី ដោយមូលហេតុរំលោភនីតិវិធី, D264/2/6, ១០ ខែ សីហា ឆ្នាំ ២០១០

**១.ពាក្យគន្លឹះ៖** ការរំលោភនីតិវិធី, ការបំពានសិទ្ធិធ្ងន់ធ្ងរ, តួនាទីរបស់ចៅក្រមស៊ើបអង្កេត, មោឃៈភាព, ការផ្អាកនីតិវិធី, វិការៈនីតិវិធី

**២. នីតិវិធី៖** ក្នុងដំណើរការនីតិវិធី លោកស្រី **អៀង ធីរិទ្ធ** ដែលជាជនជាប់ចោទម្នាក់ បានលើកវិការៈតូចៗ ចំនួន៧ ដែលជាសរុប ចាត់ជាវិការៈនីតិវិធីធ្ងន់ធ្ងរ ឬបំពាននីតិវិធីមួយ ដោយសហចៅក្រមស៊ើបអង្កេត ដែលអង្គបុរេជំនុំជម្រះ ត្រូវផ្អាកនីតិវិធីជាអចិន្ត្រៃយ៍ ប្រឆាំងនឹងគាត់។ វិការៈនោះមានដូចជា ១. សហចៅក្រមស៊ើបអង្កេតបកស្រាយខុសនូវ វិធានទី៥៦ នៃវិធានផ្ទៃក្នុងរបស់ អវតក។ ២. ប្រើប្រាស់ស្តង់ដា (standard of proof) សម្រាប់បណ្តឹងជិតចិត្ត ជាដើម...។ សហព្រះរាជអាជ្ញា ជាដំបូង សូមឲ្យបដិសេធបណ្តឹងឧទ្ធរណ៍នេះ ដោយសារ មិនមានភស្តុតាងគាំទ្រ បង្ហាញថាមានការបំពានសិទ្ធិធ្ងន់ធ្ងរ ដែលនាំឲ្យមានការផ្អាកនីតិវិធី។

## ៣. សំអាងហេតុ និងសេចក្តីសម្រេច

**ក.** PTC យល់ថាតាមវិធានទី ៧៤(៣) នៃវិធានផ្ទៃក្នុងរបស់ អវតក ជនជាប់ចោទមិនអាចប្តឹងឧទ្ធរណ៍ប្រឆាំងនឹង ដីកាបដិសេធសំណើសុំផ្អាកនីតិវិធីទេ ទោះបីជាយ៉ាងនេះក្តី ដោយគោរពតាមផលប្រយោជន៍យុត្តិធម៌ និងភាពត្រឹមត្រូវនៃនីតិវិធី (វិធានទី២១នៃវិធានផ្ទៃក្នុង) អង្គនេះ បានបកស្រាយទូលាយនូវវិធានពាក់ព័ន្ធ ហើយទទួលយកបណ្តឹងឧទ្ធរណ៍ (ទោះបីមានកំហុសបច្ចេកទេសតិចតួចក្តី)។

**ខ.** ដើម្បីផ្អាកនីតិវិធី ដែលជាវិធានការចុងក្រោយ ជនជាប់ចោទ ត្រូវបង្ហាញថា មានការបំពានសិទ្ធិធ្ងន់ធ្ងរដោយសារទង្វើស៊ើបសួរ (judicial conduct) ឬ ការបំពាននីតិវិធី ប៉ះដល់ផលប្រយោជន៍របស់ខ្លួន (ផលប្រយោជន៍គឺជាសិទ្ធិ)។ បន្ថែមពីលើនេះ ជនជាប់ត្រូវបង្ហាញថា គ្មានដំណោះស្រាយណាផ្សេង (ដូចជាសុំមោឃៈភាព) ក្រៅពីការផ្អាកនីតិវិធី ដែលជាជម្រើសចុងក្រោយបំផុត។ ជនជាប់ចោទត្រូវចង្អុលឲ្យច្បាស់នូវផ្នែកណាមួយនៃកិច្ចស៊ើបសួរ ដែលមានវិការៈ ក្នុងកម្រិតភស្តុតាងតាងខ្ពស់ (high threshold)។ កម្រិតភស្តុតាង ត្រឹម ៥១ភាគរយ (balance of probability) ស្នើដោយជនជាប់ចោទសម្រាប់ផ្អាកនីតិវិធី មិនគ្រប់គ្រាន់ទេ។ លោកស្រី អៀង ធីរិទ្ធ គ្រាន់បង្ហាញជារួម ផ្តុំនូវកំហុសតូចៗក្នុងនីតិវិធី ហើយក្នុងករណីខ្លះ ហាក់គ្រាន់តែសន្មត់ថាមានវិការៈ ឬការបំពានសិទ្ធិ ដោយមិនបានបង្ហាញ

ជាក់លាក់។ អាស្រ័យហេតុនេះ អង្គបុរេជំនុំជម្រះ រកមិនឃើញថា មានការបំពាននីតិវិធីធ្ងន់ធ្ងរ នាំឲ្យមានការផ្អាកនីតិវិធី តាមការស្នើសុំឡើយ។

៤. កំណត់សំគាល់ (ខ្លឹមសារល្អសម្រាប់ដកស្រង់)

*...ទ្រឹស្តីស្តីពីការរំលោភលើនីតិវិធី ដែលមានដើមកំណើតនៅក្នុងប្រព័ន្ធច្បាប់ខំមិនឡូ នាពេលបច្ចុប្បន្ននេះ ត្រូវបានទទួលស្គាល់ថាជាផ្នែកមួយនៃច្បាប់អន្តរជាតិ និងជាការអនុវត្តអន្តរជាតិ ដើម្បីធានាថា ការរំលោភបំពានធ្ងន់ធ្ងរនានាលើកិច្ច ឬលើនីតិវិធីដែលមិនត្រឹមត្រូវ ឬខុសច្បាស់ទាំងស្រុងនោះ មិនត្រូវបានអនុញ្ញាតឲ្យមាន ដើម្បីលុបចោលនូវសិទ្ធិទទួលបាននូវការជំនុំជម្រះក្តីដោយយុត្តិធម៌ ដែលត្រូវបានផ្តល់ឲ្យជនជាប់ចោទ ឬជនជាប់ចោទនៅចំពោះមុខតុលាការនោះទេ* (កថាខ័ណ្ឌទី១០)។

*ទ្រឹស្តីស្តីពីការរំលោភនីតិវិធីគឺជា នីតិវិធីដែលអនុញ្ញាតឲ្យចៅក្រម អាចបដិសេធការអនុវត្តតាមយុត្តាធិការរបស់តុលាការ ក្នុងករណីដែលការអនុវត្តឆន្ទានុសិទ្ធិនេះ អាចនាំឲ្យមានការបំពានធ្ងន់ធ្ងរ និងជាក់ស្តែងទៅលើសិទ្ធិជនជាប់ចោទ ហើយនឹងនាំឲ្យអន្តរាយដល់សុចរិតភាពរបស់តុលាការ។ តុលាការអាចសំអាងទ្រឹស្តីស្តីពីការរំលោភនីតិវិធីថា ជាឆន្ទានុសិទ្ធិ ហើយចៅក្រមអាចរកឃើញថា មានការរំលោភនីតិវិធី និងសម្រេចថា មិនអនុវត្តយុត្តាធិការរបស់ខ្លួន ដោយតម្កល់រឿងទុកឥតចាត់ការ ដែលមានអានុភាពបញ្ចប់នីតិវិធីទាំងស្រុង* (កថាខ័ណ្ឌទី២២)។

*អង្គជំនុំជម្រះសាលាឧទ្ធរណ៍ បានបញ្ជាក់ថា បទដ្ឋានជាធរមាន បានបំភ្លឺបន្ថែមដោយបញ្ជាក់ថា តាមឆន្ទានុសិទ្ធិរបស់ខ្លួន តុលាការ អាចសម្រេចមិនអនុវត្តយុត្តាធិការ ក្នុងករណីដែលការអនុវត្តឆន្ទានុសិទ្ធិនោះ អាចនាំឲ្យមានការបំពានធ្ងន់ធ្ងរ និងជាក់ស្តែងទៅលើសិទ្ធិរបស់ជនជាប់ចោទ ហើយនឹងនាំឲ្យអន្តរាយដល់សុចរិតភាពរបស់តុលាការ* (កថាខ័ណ្ឌទី២៣)។

ទស្សនៈទាំងស្រុងសូមមើល៖ [ECCC Pre-Trial Chamber Decision on IENG Thirith Appeal Relating to Request for Stay of Proceedings on the Basis of Abuse of Process, D264/2/6, 10 August 2010]